ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៤៣ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ភារកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យធ្វើសវនកម្មគណនេយ្យសហគ្រាស

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ខែ កក្កដា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ
- បានឃើញអនុក្រឹត្យលេខ ៧៨/អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០០៤ស្តីពីការបំពេញបន្ថែម និងការកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ/បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសមាសភាព និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ
- បានឃើញអនុក្រឹត្យលេខ ១៨/អនក្រ/បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
- បានឃើញរបាយការណ៍អង្គប្រជុំថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៦ របស់ក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
- បានឃើញកំណត់ហេតុអង្គប្រជុំ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០០៧ របស់ក្រុមប្រឹក្សាជាតិគណនេយ្យ

## សំរេច

**ប្រការ ១ :** ដោយអនុលោមទៅតាមមាត្រា ១៦ នៃច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ សហគ្រាសគ្រប់ប្រភេទជារូបវន្តបុគ្គល ឬនិតិបុគ្គល សញ្ជាតិខ្មែរ ឬបរទេស ដែលបោះទីតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដែលស្ថិតនៅក្នុងលក្ខណៈវិនិច្ឆ័យពីរ ក្នុងចំណោមលក្ខណៈវិនិច្ឆ័យបី ដូចបញ្ជាក់ខាងក្រោម មានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំការិយបរិច្ឆេទនីមួយៗរបស់ខ្លួនឱ្យសវនករឯករាជ្យ ដែលបានចុះឈ្មោះក្នុងតារាងវិជ្ជាជីវៈសវនករប្រតិស្រុតនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករ កម្ពុជា ធ្វើសវនកម្មទៅតាមច្បាប់ជាធរមាន គឺ :

- លក្ខណៈវិនិច្ឆ័យទី ១ : មានទឹកប្រាក់ផលរបរប្រចាំឆ្នាំចាប់ពី ៣.០០០.០០០.០០០ រៀល (បីពាន់លានរៀល) ឡើងទៅ
- លក្ខណៈវិនិច្ឆ័យទី ២ : មានទ្រព្យសកម្មសរុបចាប់ពី ២.០០០.០០០.០០០ រៀល (ពីរពាន់លានរៀល) ឡើងទៅ ដោយយោងទៅតាមតម្លៃទ្រព្យសកម្មមធ្យមភាគដែលមានក្នុងឆ្នាំតម្រូវឱ្យធ្វើសវនកម្ម
- លក្ខណៈវិនិច្ឆ័យទី ៣ : មានចំនួននិយោជិតបម្រើការងារចាប់ពី ១០០ (មួយរយ)នាក់ ឡើងទៅ ដោយយោងទៅតាមចំនួននិយោជិតមធ្យមភាគ ដែលមានក្នុងឆ្នាំ តម្រូវឱ្យធ្វើសវនកម្ម ។

**ប្រការ ២ :** រាល់គំរោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបានចុះឈ្មោះនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុលោមទៅតាមច្បាប់ស្តីពីវិនិយោគ មានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំការិយបរិច្ឆេទនីមួយៗរបស់ខ្លួនឱ្យសវនករឯករាជ្យ ដែលបានចុះឈ្មោះក្នុងតារាងវិជ្ជាជីវៈសវនករប្រតិស្រុតនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ធ្វើសវនកម្ម។

**ប្រការ ៣ :** រាល់សហគ្រាសដែលបានចែងក្នុងប្រការ១ និងប្រការ២នៃប្រកាសនេះ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា (សគក) ។ គ្រប់សហគ្រាសក៏ត្រូវតែបន្តរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងត្រូវតែបានធ្វើសវនកម្មឯករាជ្យក្នុងឆ្នាំបន្តបន្ទាប់ ក្រោយពីមានការធ្វើសវនកម្មលើកដំបូង ទោះបីសហគ្រាសទាំងនោះមិនបានបំពេញ គ្រប់លក្ខណៈវិនិច្ឆ័យ ដូចបានចែងនៅប្រការ១ ក៏ដោយ ។

**ប្រការ ៤ :** របាយការណ៍ហិរញ្ញវត្ថុតាមស្មារតីប្រកាសនេះរួមមាន តារាងតុល្យការ របាយការណ៍លទ្ធផល តារាងចលនាសាច់ប្រាក់ និងកំណត់សម្គាល់ ដូចបានចែងក្នុងមាត្រា៨ នៃច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ។

**ប្រការ ៥ :** រាល់សហគ្រាសអាចស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវបដិប្បញ្ញត្តិដូចតទៅ :

១. ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមតាមស្តង់ដារគណនេយ្យកម្ពុជា និង

២. ការដាក់ឱ្យធ្វើសវនកម្មដោយសវនករឯករាជ្យ

ប្រសិនបើសហគ្រាសសាម៉ីនោះ មិនមានសកម្មភាពពាណិជ្ជកម្ម ក្នុងរយៈពេលលើសពី ១២ខែ បន្ទាប់ពីមានការធ្វើសវនកម្ម នៅឆ្នាំមុន ។

**ប្រការ ៦ :** រាល់សវនកម្មត្រូវតែបានធ្វើឡើងសម្រាប់ការិយបរិច្ឆេទដែលបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ ឬ កាលបរិច្ឆេទផ្សេងពីថ្ងៃទី៣១ ខែធ្នូ ប្រសិនបើកាលបរិច្ឆេទផ្សេងនោះទទួលបានការយល់ព្រម ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ឆ្នាំដែលត្រូវធ្វើសវនកម្មជាលើកទីមួយ គឺការិយបរិច្ឆេទ ដែលបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៧ ឬក្រោយថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ប្រសិនបើ កាលបរិច្ឆេទបិទបញ្ជីគណនេយ្យបញ្ចប់នៅថ្ងៃផ្សេងពី៣១ ខែធ្នូ។ សវនកម្មត្រូវតែបានបញ្ចប់ ក្នុងរយៈពេល ៦ ខែ បន្ទាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ ។

**ប្រការ ៧ :** របាយការណ៍ហិរញ្ញវត្ថុត្រូវតែបានធ្វើសវនកម្មដោយសវនករឯករាជ្យ ដែលបានចុះឈ្មោះក្នុង តារាង វិជ្ជាជីវៈសវនករប្រតិស្រុតនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ។

**ប្រការ ៨ :** ក្រុមប្រឹក្សាជាតិគណនេយ្យ អគ្គលេខាធិការដ្ឋាន ខុទ្ទកាល័យ នាយកដ្ឋានពន្ធដារ គ្រប់នាយកដ្ឋាន អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហគ្រាសរដ្ឋ សហគ្រាសចំរុះរដ្ឋ សហគ្រាសឯកជន និងបុគ្គល ដែលពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះឱ្យ មានប្រសិទ្ធភាពចាប់ពី ថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០០៧

គាត ឈន់

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អាជ្ញាធរសវនកម្មជាតិ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលាខេត្ត-ក្រុង
- ដូចប្រការ ៨
  " ដើម្បីអនុវត្ត "
- ឯកសារ/កាលប្បវត្តិ